# សុន្ទរកថាគន្លឹះ

## របស់សម្តេច ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ថ្លែងនៅក្នុង

## វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី១

## ភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧

****+****

- ***ឯកឧត្តមប្រធានវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា***
- ***ឯកឧត្តម លោកជំទាវ តំណាងដ៏ខ្ពង់ខ្ពស់របស់ប្រទេស និង ភ្នាក់ងារជាដៃគូ***
- ***ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា នៃរាជរដ្ឋាភិបាលកម្ពុជា***
- ***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

1. ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង ក្តីសោមនស្សរីករាយជាអនេក ដោយបានមកជួបប្រជុំជាមួយតំណាងរបស់សហគមន៍អន្តរជាតិ និង ដៃគូអភិវឌ្ឍន៍ជាថ្មីម្តងទៀត ។ ខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់គ្នា និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមក្នុង **«វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា»** *(Cambodia Development Co-operation Forum-CDCF)* លើកទី ១ នាពេលនេះ ។

2. ជាមួយគ្នានេះ ខ្ញុំសូមសំដែងការវាយតម្លៃខ្ពស់ចំពោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយធនាគារពិភពលោក និង ដៃគូឯទៀតដែលមានការពាក់ព័ន្ធ ក្នុងការសម្របសម្រួលកិច្ច-ដំណើរការនៃ **«វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា»** ក្នុងរយៈពេលកន្លងមក និង ក្នុងការរៀបចំកិច្ចប្រជុំថ្ងៃនេះ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះដៃគូសហប្រតិបត្តិការទ្វេភាគី និង ពហុភាគីទាំងឡាយ ដែលបានរួមចំណែកយ៉ាងសកម្ម និងផ្តល់ការគាំទ្រដ៏សប្បុរស ដល់ការខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់របស់រាជរដ្ឋាភិបាល ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង ដើម្បីបុព្វហេតុនៃការអភិ-វឌ្ឍកម្ពុជា ។

3. ជាកិច្ចចាប់ផ្តើម ខ្ញុំសូមអនុញ្ញាតធ្វើការគូសបញ្ជាក់ថា ការផ្លាស់ប្តូរពី **«កិច្ចប្រជុំពិគ្រោះយោបល់»** មកជា **«វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា»** វិញ ដែលយើងកំពុងដំណើរការនាពេលនេះ ពិតជាមានអត្ថន័យដ៏ជ្រាលជ្រៅបំផុតសម្រាប់យើងទាំងអស់គ្នា ។ និយាយជារួម ការវិវត្តន៍ផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ជាបន្តបន្ទាប់ ចាប់តាំងពី ***«សន្និសីទថ្នាក់រដ្ឋមន្ត្រីស្តីពីការស្តារនិងកសាងកម្ពុជា ឡើងវិញ»*** ក្នុងខែ មិថុនា ឆ្នាំ ១៩៩២ និងបន្ទាប់មក ***ICORC*** ចាប់ពីឆ្នាំ ១៩៩៣ ព្រមទាំងក្រោយមកទៀតមាន ***«ការប្រជុំពិគ្រោះយោបល់» (CG)*** រហូតមកដល់ ***«វេទិកាកិច្ច***

***សហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា»*** នាពេលនេះ វាគឺជាដំណើរការដែលឆ្លុះបញ្ចាំងឱ្យឃើញពីការងើបឈរកាន់តែរឹងមាំឡើងៗ បន្តិចម្តងៗ ក្នុងន័យនៃការកសាង សមត្ថភាព ការទទួលខុសត្រូវ និង ភាពជាម្ចាស់លើការងារអភិវឌ្ឍន៍របស់កម្ពុជាខ្លួនឯងផ្ទាល់ផង និងឆ្លុះបញ្ចាំង ឱ្យឃើញអំពីបម្លាស់ប្តូរជាវិជ្ជមាននៅក្នុងការផ្តត់គំនិតរបស់សហគមន៍សហប្រតិបត្តិការក្រៅប្រទេស មកលើ ប្រទេសទទួលជំនួយ និយាយជារួម និង មកលើកម្ពុជា និយាយដោយឡែក ផងដែរ ។ ក្នុងស្មារតីនេះ ខ្ញុំសូម យកឱកាសនេះ ដើម្បីសំដែងនូវការកោតសសើរដ៏ស្មោះជូនដល់ឯកឧត្តមទេសរដ្ឋមន្ត្រី **គាត ឈន់** និង សហការីទាំងអស់របស់ឯកឧត្តមនៅក្នុងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា ចំពោះឆន្ទៈដ៏មោះមុត និង ការប្តេជ្ញាចិត្តលះបង់ខ្ពស់ ក្នុងការបំពេញភារកិច្ចត្រៀមរៀបចំសម្រាប់ការ- ប្រជុំនៃវេទិកាដ៏មានសារៈសំខាន់នេះ ។

4. ដូចពេលមុនៗដែរ យើងចូលរួមក្នុងកិច្ចប្រជុំលើកនេះ គឺមិនមែនគ្រាន់តែដើម្បីធ្វើការបូកសរុបលទ្ធផលការងារ វឌ្ឍនភាព និង ពិនិត្យឡើងវិញនូវសកម្មភាពកំណែទម្រង់របស់យើង ក្នុងរយៈពេលកន្លងមកប៉ុណ្ណោះទេ ប៉ុន្តែ យើងក៏នឹងធ្វើការពិគ្រោះយោបល់ផងដែរ លើទិដ្ឋភាពគន្លឹះផ្សេងៗនៃអភិក្រមជាយុទ្ធសាស្ត្រ សម្រាប់ការជំរុញកិច្ចដំណើរការអភិវឌ្ឍកម្ពុជា នាពេលខាងមុខ ។ ក្នុងស្មារតីនេះ នៅក្នុងបទអន្តរាគមន៍របស់ខ្ញុំនាព្រឹកនេះ ជាដំបូង ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ ដោយសង្ខេប អំពីសមិទ្ធិផលធំៗ និង បញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលយើងសម្រេចបាន និង បានជួបប្រទះ ក្នុងរយៈពេលថ្មីៗ កន្លងមកនេះ ។ ជាមួយគ្នានេះដែរ ខ្ញុំនឹងលើកឡើងអំពីបញ្ហាគោលនយោបាយចម្បងៗមួយចំនួន ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍ ក៏ដូចជាដើម្បីទាក់-ទាញនូវការគាំទ្របន្ថែមទៀត ពីសំណាក់ដៃគូសហប្រតិបត្តិការទាំងអស់របស់យើង ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

5. ក្នុងរយៈពេលជិតមួយទស្សវត្សរ៍ចុងក្រោយនេះ កម្ពុជាសម្រេចបាននូវផ្លាស់ប្តូរមុខមាត់ជាវិជ្ជមានយ៉ាងច្រើន ។ នយោបាយ ***«ឈ្នះ-ឈ្នះ»*** ដែលយើងបានដាក់ចេញមកដោយខ្លួនឯង ដោយគ្មានការចង្អុលបង្ហាញ ឬ បញ្ចុះបញ្ចូលពីខាងក្រៅ បាននាំមកជូនប្រទេស និង ប្រជាជនកម្ពុជា នូវសុខសន្តិភាព ការបង្រួបបង្រួមជាតិ និង ការឯកភាពទឹកដី ដ៏ពេញលេញ និង ពិតប្រាកដ នៅចុងឆ្នាំ ១៩៩៨ ។ ក្នុងរយៈពេល ៨ ឆ្នាំកន្លងទៅនេះ ប្រទេស និង ប្រជាជនកម្ពុជា បាន និងកំពុងតែសប្បាយរីករាយ ក្នុងការទទួលផលពីសុខសន្តិភាព ស្ថិរភាពនយោបាយ និង កំណើនសេដ្ឋកិច្ចដ៏លឿន ។ ជាការពិត សុខសន្តិភាពដែលសម្រេចបានមកដោយលំបាកលំបិន ស្ថិរភាពនយោបាយ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និង បរិយាកាសសន្តិសុខដ៏គត់មត់ទាំងអស់នេះ កំពុងតែបន្តដើរតួនាទីជាបុព្វលក្ខខណ្ឌដ៏សំខាន់បំផុត ដែលអនុញ្ញាតឱ្យកម្ពុជាប្រែក្លាយឱ្យចេញមកជាការជាក់ស្តែង នូវសក្តានុពលសេដ្ឋកិច្ច និង សង្គម របស់ជាតិ ។

6. នៅលើមូលដ្ឋាននៃសុខសន្តិភាព និង ស្ថិរភាព ដែលមានលក្ខណៈកាន់តែរឹងមាំឡើងៗពីមួយថ្ងៃទៅមួយថ្ងៃនេះ រាជរដ្ឋាភិបាលបានជំរុញអនុវត្តប្រកបដោយឆន្ទៈមោះមុតបំផុតនូវកំណែទម្រង់គ្រប់ផ្នែក គ្រប់វិស័យនៅ ក្នុងក្របខ័ណ្ឌនៃ ***«យុទ្ធសាស្ត្រចតុកោណ» ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** និង

***«ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍជាតិ»*** ។ ការខិតខំទាំងអស់នេះ បានចាក់ឫសយ៉ាងជ្រៅទៅក្នុងមូលដ្ឋាននៃសង្គម- សេដ្ឋកិច្ចកម្ពុជា ហើយបានធ្វើឱ្យសេដ្ឋកិច្ចជាតិ មានការរីកចម្រើនយ៉ាងឆាប់រហ័ស ។

7. ជាក់ស្តែង ក្រោយពីកម្ពុជាសម្រេចបាននូវសុខសន្តិភាពពេញលេញ នៅឆ្នាំ ១៩៩៩ មក ទោះបីជាមានបញ្ហាប្រឈមធំៗមួយចំនួននៅក្នុងស្ថានការណ៍សេដ្ឋកិច្ចតំបន់ និង ពិភពលោក ព្រមទាំងមានគ្រោះធម្មជាតិមិនអំណោយផលមួយចំនួននៅផ្ទៃក្នុងប្រទេសក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅតែអាចប្រមូលផ្តុំបាននូវថាមពលកាន់តែរឹងប៉ឹងឡើងជាប់ជាលំដាប់ ហើយសម្រេចបាននូវកំណើនក្នុងអត្រាជាមធ្យម ប្រមាណ ៩,៤% ក្នុងមួយឆ្នាំៗ នៅក្នុងរយៈពេលពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៦ ។ ដោយឡែក នៅក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ កំណើនសេដ្ឋកិច្ចសម្រេចបានក្នុងសន្ទុះខ្ពស់មិនធ្លាប់មាន ក្នុងអត្រាជាមធ្យម ១១,៤ % ក្នុងមួយឆ្នាំ ។ ជាពិសេស នៅក្នុងឆ្នាំ ២០០៥ អត្រាកំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់បំផុតរហូតដល់ទៅ ១៣,៥% ហើយនៅឆ្នាំ ២០០៦ កន្លងទៅនេះ កំណើនសេដ្ឋកិច្ចសម្រេចបាន ១០,៨% ។ ចំណូលសម្រាប់មនុស្សម្នាក់ៗជាមធ្យម បានកើនឡើងជិតទ្វេដង គឺពី ២៨៨ ដុល្លារ ក្នុងឆ្នាំ ២០០០ រហូតដល់ ៥១៣ ដុល្លារ នៅឆ្នាំ ២០០៦ ។ អត្រាអតិផរណា ត្រូវបានរក្សាឱ្យស្ថិតនៅក្នុងកម្រិតទាបជាមធ្យមនៅក្រោម ៣% ក្នុងចន្លោះពេលពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៦ ។ អត្រាប្តូរប្រាក់ក៏មានស្ថិរភាពជាទូទៅផងដែរ ។ ក្នុងរយៈពេលដដែលនេះ ទុនបម្រុងអន្តរជាតិរបស់ប្រទេស បានកើនឡើងជាងទ្វេដង ពីប្រមាណជិត ៥០០ លានដុល្លារអាមេរិក នៅឆ្នាំ ២០០០ ដល់ជាង ១ ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០០៦ ។ ក្នុងឆ្នាំ ២០០៧ នេះ កំណើនសេដ្ឋកិច្ច ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានក្នុងរង្វង់ជុំវិញ ៩% ។ អតិផរណានឹងបន្តស្ថិតនៅក្នុងកម្រិតទាបក្រោម ៥% ។ អត្រាប្តូរប្រាក់មានស្ថិរភាពល្អជាទូទៅ ។ ទុនបម្រុងអន្តរជាតិនឹងបន្តកើនឡើង ដែលអាចធានាការនាំចូលក្នុងរង្វង់ ៣ ខែ ។

8. ជាការពិត រាជរដ្ឋាភិបាលទទួលស្គាល់ថា សមិទ្ធិផលទាំងអស់នេះ មិនអាចកាត់ផ្តាច់បានទេ ពីការចូលរួមវិភាគទានដ៏សប្បុរសរបស់ដៃគូសហប្រតិបត្តិការទាំងឡាយរបស់កម្ពុជា ។ វាក៏ឆ្លុះបញ្ចាំងឱ្យឃើញផងដែរ នូវប្រសិទ្ធភាព និង ភាពសក្តិសិទ្ធិ ដែលត្រូវបានកែលំអឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ នៃការប្រើ-ប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការគ្រប់ប្រភេទ ដែលកម្ពុជាទទួលបានពីដៃគូសហប្រតិបត្តិការក្រៅប្រទេសរបស់ខ្លួន ក្នុងរយៈពេលកន្លងមកនេះ ។ ដូច្នេះ ឆ្លៀតក្នុងឱកាសដ៏កម្រ និង ដ៏អធិកអធម នាពេលនេះ ខ្ញុំសូមតាងនាមឱ្យរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជាទាំងមូល ថ្លែងនូវអំណរគុណដ៏ស្មោះអស់ពីដួងចិត្ត ជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមវិភាគទានដ៏ឧត្តុងឧត្តមមិនអាចកាត់ថ្លៃបានទាំងអស់នេះ ដើម្បីបុព្វ-ហេតុនៃការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍកម្ពុជា ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

9. សមិទ្ធផលដ៏គួរជាទីមោទនៈទាំងឡាយដែលយើងសម្រេចបានមកនេះ បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថា កម្ពុជាបានដាក់ឱ្យនៅពីក្រោយខ្នងរបស់ខ្លួននូវវប្បធម៌ទំនាស់ និង សង្គ្រាម ដោយមិនងាកត្រឡប់មកវិញ ហើយយើងទាំងអស់គ្នាកំពុងតែសម្លឹងទៅមុខឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង តាមរយៈការខិតខំពង្រឹងនូវវប្បធម៌សន្តិភាព និង ការផ្សះផ្សាជាតិ ការលើកស្ទួយលិទ្ធិប្រជាធិបតេយ្យសេរី ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូរ

របស់មនុស្ស ការការពារសន្តិសុខ សុវត្ថិភាព ស្ថិរភាព និង សណ្តាប់ធ្នាប់សង្គម ការកែលំអអភិបាលកិច្ច ដើម្បីលើកស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈ និង សមធមិសង្គម និង ការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ដើម្បីអភិវឌ្ឍន៍ ។

10. ដូចខ្ញុំបានគូសបញ្ជាក់ពីខាងលើ ជាមួយនឹងកាលានុវត្តភាពដ៏កម្រ ដែលប្រទេស និងប្រជាជនកម្ពុជាទទួលបានពីសុខសន្តិភាព ការបង្រួបបង្រួមជាតិ និង ការឯកភាពទឹកដី នៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយអង្គ និង រាជរដ្ឋាភិបាលតែមួយ យើងបានខិតខំជំរុញអនុវត្តយ៉ាងសកម្មបំផុត នូវគោល-នយោបាយ យុទ្ធសាស្ត្រ កម្មវិធីកំណែទម្រង់ និង ផែនការអភិវឌ្ឍន៍របស់យើង គ្រប់ផ្នែក គ្រប់វិស័យ ដែលសម្រេចបានមកជាផ្លែផ្កាគួរជាទីកត់សម្គាល់ និង គួរជាទីលើកទឹកចិត្ត ។ នៅពេលបន្តិចទៀតនេះ ឯកឧត្តម **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ នឹងធ្វើរបាយរការណ៍ និង បទបង្ហាញជូនអង្គវេទិកាជ្រាប អំពីវឌ្ឍនភាពទាំងឡាយ ដែលយើងសម្រេចបាននៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់យើង នៅក្នុងឆ្នាំកន្លងមក ។ ខ្ញុំក៏បានដឹងផងដែរថា ក្នុងរយៈពេលជាងមួយឆ្នាំកន្លងទៅនេះ ដៃគូអភិវឌ្ឍន៍ទាំងអស់របស់យើងបានធ្វើការយ៉ាងស្អិតរមួតជាមួយនឹងសមភាគីរបស់ខ្លួន នៅក្នុងក្របខ័ណ្ឌនៃក្រុមការងារបច្ចេកទេស និង គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ។

11. ដូច្នេះ នៅពេលនេះ ប្រហែលជាពុំមានការចាំបាច់ ដែលតម្រូវឱ្យខ្ញុំអធិប្បាយលម្អិតគ្រប់ជ្រុងជ្រោយអំពីសមិទ្ធផលទាំងឡាយដែលយើងសម្រេចបាន ក្នុងឆ្នាំកន្លងមកនោះទេ ។ ក៏ប៉ុន្តែ យ៉ាងណាក៏ដោយ ខ្ញុំក៏បានដឹងដែរថា ក្រុមការងារទាំងអស់មិនមែនសុទ្ធបានដំណើរការដោយរលូនជាប់ជាប្រចាំនោះទេ ហើយសមិទ្ធផលទាំងឡាយដែលយើងសម្រេចបាន បើធៀបទៅនឹងគោលដៅដើមដែលយើងបានឯកភាពគ្នាដាក់ចេញមក ក៏មិនមែនសុទ្ធតែសុក្រឹត្យទាំងអស់នោះដែរ ។ ហេតុនេះ ខ្ញុំយល់ថា ខ្ញុំគួរតែឆ្លៀតយកឱកាសនេះ ធ្វើការគូសរំលេចឱ្យឃើញអំពីចំណុចសំខាន់ៗជាគន្លឹះមួយចំនួនធំ ដែលជាកង្វល់រួមរបស់យើងទាំងអស់គ្នា ទាំងសម្រាប់រាជរដ្ឋា-ភិបាល ទាំងសម្រាប់ដៃគូអភិវឌ្ឍន៍នៅទីនេះ ។

12. ខ្ញុំសូមចាប់ផ្តើមពីស្នូលរបស់ «**យុទ្ធសាស្ត្រចតុកោណ**» ពោលគឺ កំណែទម្រង់អភិបាលកិច្ច ។ អាទិ-ភាពសំខាន់របស់យើងនៅក្នុងវិស័យអភិបាលកិច្ច គឺការខិតខំប្រឹងប្រែងលើកកម្ពស់សមត្ថភាព និង ប្រសិទ្ធភាពនៃវិស័យសាធាណរៈ ដោយរួមបញ្ចូលទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយផង នៅលើការដ្ឋានច្រើនផ្សេងៗគ្នា រួមមាន ការជំរុញអនុវត្តកំណែទម្រង់ប្រព័ន្ធច្បាប់ និង តុលាការ ការកែលំអប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈ និង ការកែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងការងារវិមជ្ឈការ និង វិសហមជ្ឈការផងដែរ ។

13. បើពិនិត្យលើសមិទ្ធផលជាគន្លឹះមួយចំនួនដែលសម្រេចបានក្នុងរយៈពេលដ៏ខ្លីកន្លងទៅនេះ ជាពិសេសសមិទ្ធផលនៅក្នុងការតាក់តែង និង អនុម័តច្បាប់គ្រឹះមួយចំនួន ដូចជា ក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមនីតិវិធីព្រហ្មទណ្ឌ ជាដើម ក៏ដូចជាសមិទ្ធផលផ្សេងទៀតនៅក្នុងការខិតខំពង្រឹងស្ថាប័នតុលាការ និង ការកសាងធន-ធានមនុស្ស វាបានបង្ហាញអំពីវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នៅក្នុងការខិតខំរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញកិច្ចការកែទម្រង់នៅក្នុងវិស័យប្រព័ន្ធច្បាប់ និង តុលាការនេះ ។ ជាការពិត យើងទាំងអស់គ្នាដឹងថា យើងនៅមានបញ្ជីនៃរបៀបវារៈដ៏វែងនៅឡើយ នៅលើការដ្ឋានកំណែទម្រង់នេះ ដែលក្នុងពេលបច្ចុប្បន្ន វាកំពុងតែហែក

ទាញសមត្ថភាពដ៏ស្តួចស្តើងរបស់កម្ពុជា ដល់កម្រិតមួយដ៏តឹងតែងណាស់ទៅហើយ ។ យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលនៅតែមានការប្តេជ្ញាចិត្តដ៏មុតស្រួចក្នុងការជំរុញអនុវត្តកំណែទម្រង់ដ៏ធំធេង និង លំបាកលំបិននេះ ឱ្យបានកាន់តែក្លៀវក្លាតទៅទៀត ដើម្បីលើកកម្ពស់ស្ថានភាពប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេស ឱ្យកាន់តែប្រសើរឡើង ។

14. ទន្ទឹមនឹងនេះ ខ្ញុំក៏បានដឹងថា មានដៃគូជាច្រើននៅតែសំដែងការព្រួយបារម្ភអំពីស្ថានភាពមិនច្បាស់លាស់ខ្លះៗ នៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ។ ពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលពិតជាមានការប្តេជ្ញាចិត្តមោះមុតឥតរាថយ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ ដោយយើងបានធ្វើសកម្មភាពជាក់ស្តែងដ៏ច្រើនរាប់មិនអស់រួចមកហើយ ដើម្បីគោលដៅនេះ រួមមានទាំងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយផងដែរ ។ ក៏ប៉ុន្តែ បើទោះជាយើងប្រញាប់យ៉ាងណាក៏ដោយ យើងគួរតែដាក់ការងារនេះ ទៅក្នុងបរិការណ៍នៃសេចក្តីត្រូវការរួម និង ស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា ។ ក្រោយពីងើបចេញផុតពីសង្រ្គាមបំផ្លិចបំផ្លាញដែលបង្ករឡើងនៅក្រោមឥទ្ធិពលពីខាងក្រៅ ក្រោយពីបានឆ្លងកាត់របបប្រល័យពូជសាសន៍ដ៏សាហាវយង់ឃ្នង ហើយបន្ទាប់មកទៀត គឺបានឆ្លងកាត់ការដាក់ទណ្ឌកម្មហ៊ុំព័ទ្ធខាងនយោបាយ និងសេដ្ឋកិច្ច និង ទំនាស់ផ្ទៃក្នុងដែលនៅបន្តរហូតមកពេលថ្មីៗនេះ ប្រទេសកម្ពុជាពិតជាមានសេចក្តីត្រូវការ និង អាទិភាពច្រើនបែបច្រើនយ៉ាងណាស់ នៅក្នុងពេលតែមួយជាមួយគ្នា ។ ដោយឡែក នៅក្នុងការខិតខំកសាងប្រព័ន្ធច្បាប់ និង ស្ថាប័នយុត្តិធម៌របស់ខ្លួន រាជរដ្ឋាភិបាលចង់បាននូវក្របខ័ណ្ឌគតិយុត្តិមួយដែលមានសង្គតិភាព និង ប្រសិទ្ធភាពពិតប្រាកដ ហើយអាចឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់ប្រទេសជាតិ និង ប្រជាជន ក្នុងការអភិវឌ្ឍប្រកបដោយចិរភាព ទាំងក្នុងរយៈពេលចំពោះមុខ និង ក្នុងរយៈពេលវែងខាងមុខ ។ នៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយនេះ យើងក៏បានយកគោលការណ៍នេះមកធ្វើជាមូលដ្ឋានផងដែរ ។ ដូច្នេះ វាគឺជាប្រការដ៏ចាំបាច់ណាស់ដែលយើងត្រូវធានាឱ្យបាននូវសង្គតិភាពរវាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនេះ ជាមួយនឹងបណ្តាច្បាប់ដែលមានការពាក់ព័ន្ធនានា រួមមានដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ និង ក្រមព្រហ្មទណ្ឌ ជាដើម ។ នៅក្នុងខណៈមួយដែលយើងកំពុងតែរៀបចំសេចក្តីព្រាងច្បាប់ទាំងអស់នេះ ក្នុងពេលតែមួយជាមួយគ្នា យើងយល់ថា វាគឺជាឱកាសដ៏សមស្របសម្រាប់យើងប្រើពេលវេលាមួយចំនួន ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ទាំងអស់នេះទៅតាមលំដាប់លំដោយត្រឹមត្រូវ ដែលវានឹងធានាផ្តល់ឱ្យយើងនូវភាពរលូន សង្គតិភាព និង ប្រសិទ្ធភាពនៅក្នុងការអនុវត្ត ។

15. ខ្ញុំសូមបញ្ជាក់ម្តងទៀតថា និយាយដូច្នេះ មិនមែនបានន័យថា រាជរដ្ឋាភិបាលមានចេតនាចង់ដកថយ ឬ គេចវេស ពីការទទួលខុសត្រូវក្នុងការងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនោះទេ ។ ក៏ប៉ុន្តែ យើងយល់ថា ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយនេះតែឯកឯង វាមិនមែនជាថ្នាំទិព្យតែមួយមុខគត់ ដែលអាចលុបបំបាត់អស់ភ្លាមៗ នូវជម្ងឺពុករលួយនៅក្នុងសង្គមជាតិនោះទេ ពិសេសនៅក្នុងកាលៈទេសៈដ៏បង្ខំមួយដែលគេដាក់វាចេញមកដោយខ្វះសង្គតិភាពជាមួយនឹងច្បាប់សំខាន់ៗដទៃទៀតនៅក្នុងប្រទេស ដែលប្រការនេះអាចធ្វើឱ្យការអនុវត្តច្បាប់ប្រព្រឹត្តិទៅក្នុងស្ថានភាពមិនគ្រប់ជ្រុងជ្រោយ និង ប្រទាំងប្រទើសគ្នាជាប្រចាំ ។

16. យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់ថា អំពើពុករលួយគឺជាជម្ងឺមហារីកប្រកបដោយគ្រោះថ្នាក់ ដែលយើងត្រូវតែខិតខំធ្វើការតស៊ូប្រយុទ្ធប្រឆាំងនឹងវាជាប់ជាប្រចាំ គ្រប់ពេលវេលា និង នៅក្នុងគ្រប់កាលៈទេសៈ ដោយមិនអាចបន្ធូរដៃបាន ។ នៅក្នុងស្មារតីនេះ ទោះបីជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើពុករលួយនៅឡើយក៏ដោយ ក៏នៅក្នុងរយៈពេលកន្លងមក យើងបានផ្តល់អាទិភាពជាពិសេសទៅលើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ តាមរយៈការដាក់ចេញ និង អនុវត្តនូវវិធានការមុតស្រួចមួយចំនួន នៅក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិច្បាប់ទាំងឡាយដែលមានស្រាប់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងជាច្រើន រួមមានដូចជា ការរៀបចំរចនាសម្ព័ន្ធ និងពង្រឹងអង្គភាពប្រឆាំងអំពើពុករលួយឡើងវិញ និង ការដាក់ទណ្ឌកម្មរដ្ឋបាល និង ការបញ្ជូនទៅតុលាការនូវមន្ត្រីមួយចំនួន ។ ជាឧទាហរណ៍ជាក់ស្តែង នាពេលថ្មីៗកន្លងទៅនេះមានមន្ត្រី ៧ រូប ដែលបានប្រព្រឹត្តល្មើសច្បាប់ព្រៃឈើ ត្រូវបានដាក់ឱ្យទទួលទណ្ឌកម្មរដ្ឋបាល មន្ត្រី ២ រូបត្រូវបានចោទប្រកាន់ និង កាត់ទោសឱ្យជាប់ពន្ធនាគារពីបទរំលោភលើអចលនទ្រព្យឯកជន មន្ត្រី ១ រូបត្រូវបានចោទពីបទទទួលសំណូកសមគំនិតក្នុងការរំលោភលើដីរដ្ឋ និងព្រៃឈើ និង ពីបទក្លែងបន្លំ មន្ត្រី ១ រូបត្រូវបានតុលាការចោទពីបទបំផ្លិចបំផ្លាញធនធានធម្មជាតិ និងបរិស្ថាន និង មន្ត្រី ១១ រូបទៀតត្រូវបានតុលាការកាត់ទោសពីបទកាប់ឈើខុសច្បាប់ នៅតំបន់កន្ទុយនាគនៃខេត្ត រតនៈគីរី ។

17. ទោះជាយ៉ាងណាក៏ដោយ យើងក៏នៅតែយល់ស្របគ្នាជាមួយដៃគូអភិវឌ្ឍន៍របស់យើងដែរថា ច្បាប់ប្រឆាំងនឹងអំពើពុករលួយនេះ វាគឺជាសមាសធាតុគន្លឹះមិនអាចខ្វះបានមួយ សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ នៅលើមូលដ្ឋាននេះ ទន្ទឹមនឹងសេចក្តីត្រូវការដ៏ចាំបាច់ក្នុងការធានានូវសង្គតិភាពក្នុងការតាក់តែងច្បាប់ដែលមានការពាក់ព័ន្ធគ្នា ដូចបានបញ្ជាក់ជូនពីខាងលើនេះ រាជរដ្ឋាភិបាលនៅតែមានការប្តេជ្ញាចិត្តឥតរាថយ ក្នុងការជំរុញកសាងសេចក្តីព្រាងច្បាប់នេះ ឱ្យបានសម្រេចយ៉ាងឆាប់រហ័សតាមតែអាចធ្វើទៅបាន ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តកិច្ចសហការពិគ្រោះយោបល់យ៉ាងជិតស្និទ ជា-មួយនឹងគ្រប់ដៃគូដែលមានការពាក់ព័ន្ធ ដើម្បីរិះរកមធ្យោបាយដ៏សិក្តិសិទ្ធិនានាសំដៅសម្របសម្រួលជំហរ និង ជំរុញកិច្ចការនេះ ឱ្យមានដំណើរការទៅមុខបានឆាប់រហ័សស្របតាមសេចក្តីត្រូវការរបស់កម្ពុជា ។

18. រាជរដ្ឋាភិបាលទទួលស្គាល់នូវសេចក្តីត្រូវការដ៏ចាំបាច់ ក្នុងការរៀបចំនូវរដ្ឋបាលស៊ីវិលមួយ ដែលមានលក្ខណៈសម្បត្តិ និង សមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ។ ក្នុងន័យនេះ កំណែទម្រង់រដ្ឋបាលសាធារណៈ នៅតែបន្តស្ថិតនៅជាអាទិភាពដ៏ខ្ពស់របស់យើងដដែល ។ ដើម្បីឱ្យកំណែទំរង់នេះ មានលក្ខណៈកាន់តែស៊ីជម្រៅថែមទៀតក្នុងរយៈពេលមធ្យមខាងមុខ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ បានផ្តួចផ្តើមរៀបចំគោលនយោបាយចំនួន ៦ និង ផែនការសម្រាប់អនុវត្តគោលនយោ-បាយទាំងនេះផងដែរ ។ នេះ គឺជាយុទ្ធសាស្ត្រមួយប្រកបដោយភាពរលូន និង ប្រទាក់ក្រឡាគ្នា ដែលផ្តោតការយកចិត្តទុកដាក់ដល់កំណែទម្រង់ដ៏ទូលំទូលាយ សម្រាប់រយៈពេលវែង ។ រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់ថា គន្លឹះដ៏សំខាន់បំផុតមួយនៅក្នុងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈនេះ គឺការធ្វើឱ្យប្រសើរឡើងនូវការលើកទឹកចិត្តសម្រាប់មន្ត្រីរាជការ ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាព និង ភាពស្មោះត្រង់របស់រដ្ឋ-បាលសាធារណៈទាំងមូល ។

19. ជាការពិត ថ្មីៗនេះ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានសហការគ្នាត្រួសត្រាយសាកល្បងនូវវិធាន-ការថ្មី ដើម្បីដោះស្រាយបញ្ហាទាំងនេះ ពិសេសតាមរយៈគំនិតផ្តួចផ្តើមផ្តល់បៀវត្សរ៍តាមគុណសម្បត្តិ ដែលកំពុងតែត្រូវបានអនុវត្តនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គំនិតផ្តួចផ្តើមនេះ គឺជាកម្មវិធីមួយដែលផ្តល់ការលើកទឹកចិត្តជាប្រាក់បៀវត្សរ៍ខ្ពស់ចំពោះមន្រ្តីរាជការ ស្របតាមគុណសម្បត្តិ និង ជំនាញរបស់ពួកគេ ក៏ប៉ុន្តែ ក៏តម្រូវឱ្យមានផងដែរ នូវការរៀបចំប្រព័ន្ធការងារមួយ ដែលមានការគ្រប់គ្រងដ៏ម៉ត់ចត់ ។

20. ខ្ញុំបានដឹងថា ដោយពិនិត្យឃើញជោគជ័យនៃការអនុវត្តសាកល្បងជំហានទីមួយនៃគំនិតផ្តួចផ្តើមនេះនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅពេលនេះ ក៏មានក្រសួង និង ស្ថាប័នមួយចំនួនទៀតរបស់រាជរដ្ឋាភិបាល ដូចជា ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម ។ល។ កំពុងតែស្នើសុំចាប់ផ្តើមសាកល្បងអនុវត្តគំនិតផ្តួចផ្តើមនេះដែរ ។ ដូច្នេះ ខ្ញុំសូមលើកទឹកចិត្តឱ្យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈបង្កើនកិច្ចសហការជាមួយនឹងគ្រប់ដៃគូ និង ក្រសួង- ស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តសាកល្បងគំនិតផ្តួចផ្តើមនេះ ឱ្យបានកាន់តែទូលំទូលាយថែមទៀត ស្របតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។ ជាការពិត ខ្ញុំក៏បានដឹងដែរថា គំនិតផ្តួចផ្តើមផ្តល់បៀវត្សរ៍តាមគុណសម្បត្តិនេះ វាមានលក្ខណៈពិសេសមួយចំនួនថែមទៀត បើប្រៀបធៀបទៅនឹងទស្សនាទាន ***«កន្សោមអាទិភាព»*** ដែលរាជរដ្ឋាភិបាលកំពុង តែជំរុញអនុវត្តក្នុងពេលតែមួយជាមួយគ្នានេះដែរ នៅតាមក្រសួង និង ស្ថាប័នមួយចំនួនទៀតរបស់រាជរដ្ឋា- ភិបាល ។ ដូច្នេះ ដើម្បីធានាឱ្យមានភាពច្បាស់លាស់ខាងផ្នែកទស្សនាទាន និង គោលនយោបាយ ក៏ដូចជា ដើម្បីធានាប្រសិទ្ធភាព និង ភាពរលូននៅក្នុងការអនុវត្តជាក់ស្តែង ខ្ញុំស្នើសូមឱ្យក្រសួង- ស្ថាប័នពាក់ព័ន្ធរបស់ រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍របស់យើង មេត្តាពិនិត្យលទ្ធភាពសហការគ្នារៀបចំជាកម្មសិក្ខាសាលាថ្នាក់ ជាតិមួយ នៅក្នុងពេលឆាប់ៗខាងមុខ ដើម្បីរួមគ្នាពិភាក្សាស្វែងរកកុងសង់ស៊ុសខាងទស្សនៈគោលនយោបាយ ព្រមទាំងវាយតម្លៃអំពីវឌ្ឍនភាព និង ភាពចាំបាច់ក្នុងការដាក់ចេញនូវវិធានការកែតម្រូវទាំងឡាយ សំដៅជំរុញ ល្បឿននៃកិច្ចការកែទម្រង់ដ៏មានសារៈសំខាន់នេះ ឱ្យមានសន្ទុះកាន់តែក្លៀវក្លាថែមទៀត ។

21. យោងលើសារៈសំខាន់នៃកំណែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ពិសេសគឺការងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និង កំណែទម្រង់រដ្ឋបាលសាធារណៈ ខ្ញុំបានស្នើឱ្យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ដែលជាអ្នកទទួលបន្ទុកសម្របសម្រួលផ្ទាល់លើកិច្ចការងារនេះ ចូលរួមដោយផ្ទាល់នៅក្នុងការពិភាក្សារបស់អង្គវេទិកា ដើម្បីបំភ្លឺបន្ថែម និង ឆ្លើយតបទៅនឹងកង្វល់ ព្រមទាំងការព្រួយបារម្ភទាំងឡាយរបស់ដៃគូនៅទីនេះ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

22. ការអនុវត្តន៍ប្រកបដោយជោគជ័យនូវ «**កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ**» ដែលខ្ញុំបានប្រកាសដាក់ឱ្យអនុវត្តនៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៤ បានចេញជាផ្លែផ្កាជាវិជ្ជមានគួរជាទីលើកទឹកចិត្ត ដោយសម្រេចបាននូវលទ្ធផលជាក់ស្តែងថ្មីៗជាច្រើន ដែលឆ្លុះបញ្ចាំងឡើងជាពិសេសតាមរយៈការកើនឡើងនៃភាពអាចជឿទុកចិត្តបាននៃថវិកាជាតិ ដោយសារការកើនឡើងខ្ពស់ជាបន្តបន្ទាប់នូវចំណូលថវិកា ការកែលំអការគ្រប់គ្រង

និង ចាត់ចែងចំណាយថវិកា ឱ្យបានកាន់តែមានប្រសិទ្ធភាព កាន់តែមានតម្លាភាព និង ភាពអាចប៉ាន់ប្រមាណបាន និង កាន់តែចំគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ការគ្រប់គ្រងសាចប្រាក់កាន់តែប្រសើរឡើង ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកាត់បន្ថយបានយ៉ាងច្រើននូវបំណុលកកស្ទះនៅរតនាគារជាតិ ។

23. ជាលទ្ធផលជាក់ស្តែង ចំណូលថវិកាជាតិបានកើនឡើងចំនួន ២៦% នៅក្នុងឆ្នាំ ២០០៦ កន្លងទៅនេះ ដែលក្នុងនោះចំណូលប្រមូលដោយនាយកដ្ឋានពន្ធដារបានកើនឡើងចំនួន ៣៨% ចំណូលប្រមូលដោយទីចាត់-ការគយ និង រដ្ឋាករ បានកើនឡើងចំនួន ១១% ហើយចំណូលប្រមូលពុំមែនសារពើពន្ធកើនឡើងចំនួន ៩% ។

24. ជាការពិត ការកើនឡើងនៃចំណូលថវិកាជាតិបានអនុញ្ញាតឱ្យយើងអាចធ្វើការបង្វែរទុនវិនិយោគកាន់តែច្រើនថែមទៀត ទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗ រួមមាន ផ្លូវគមនាគមន៍ដឹកជញ្ជូន និងប្រព័ន្ធធារា-សាស្ត្រ និងទៅលើការអភិវឌ្ឍសង្គម និងធនធានមនុស្ស ដែលជាកត្តាដ៏ចាំបាច់សម្រាប់បង្កើតលក្ខខណ្ឌអំណោយ-ផល ដល់ការលើកស្ទួយ និងធានាចិរភាពនៃកំណើន ក៏ដូចជាអំណោយផលដល់ការបែងចែកផលផ្លែផ្កានៃកំណើននេះ ឱ្យបានទូលំទូលាយទូទាំងផ្ទៃប្រទេសផងដែរ ។ ចាប់តាំងពីឆ្នាំ ១៩៩៩ មក រាជរដ្ឋាភិបាលបានបង្កើនឡើងយ៉ាងគំហុកនូវចំណាយលើការកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមកិច្ច ។ ជាក់ស្តែង ចំណាយថវិកាជាតិលើវិស័យសុខាភិបាលបានកើនឡើងចំនួន ៧,៦ ដង ពី ៤៤ ពាន់លានរៀល នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៣៣៧ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៧ ។ ចំណាយលើវិស័យអប់រំបានកើនឡើងជាង ៥ ដង ពី ១០២ ពាន់លានរៀល នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៥៨៦ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៧ ។ ចំណាយនៃថវិកាជាតិលើវិស័យហេដ្ឋា-រចនាសម្ព័ន្ធផ្លូវថ្នល់ មានចំនួនសរុបប្រមាណជា ១.៤០០ ពាន់លានរៀល ឬ ៣៥០ លានដុល្លារ នៅចន្លោះឆ្នាំ ២០០០ ដល់ ឆ្នាំ ២០០៦ ។

25. រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តក្នុងការបន្តជំរុញអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលបច្ចុប្បន្ននេះកំពុងតែឈានចូលទៅកាន់ការបញ្ចប់ដំណាក់កាលទីមួយ នៃការធ្វើឱ្យថវិកាជាតិមានសភាពអាចជឿទុកចិត្តបាន និង ការចាប់ផ្តើមដំណាក់កាលទីពីរ នៃការបង្កើនប្រសិទ្ធភាព និង គណនេយ្យភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងឆ្នាំ ២០០៧ នេះ រាជរដ្ឋាភិបាលនឹងបន្តប្រមូលផ្តុំការយកចិត្តទុកដាក់របស់ខ្លួនទៅលើកិច្ច-ការជាអាទិភាពមួយចំនួន រួមមាន ការជំរុញអនុវត្តឱ្យបានរលូននូវតារាងគណនីថ្មី មាតិកាថវិកាថ្មី និង ថវិកាតាមកម្មវិធី ដែលត្រូវបានដាក់ឱ្យសាកល្បងនៅតាមក្រសួងអាទិភាពទាំង ៧ ការពង្រឹងយន្តការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងប្រព័ន្ធគណនីទោលរបស់រតនាគារជាតិ និង ការបង្កើនភាពគ្រប់ជ្រុងជ្រោយនៃថវិកាជាតិ ។

26. ជាមួយគ្នានេះដែរ ដោយសារការខិតខំពុះពារយ៉ាងស្វិតស្វាញក្នុងជំរុញអនុវត្ត «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**» ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មក្នុងពេលកន្លងទៅថ្មីនេះ ប្រព័ន្ធហិរញ្ញវត្ថុរបស់ជាតិបានចាប់ផ្តើមដើរតួនាទីកាន់តែសំខាន់ឡើងៗ នៅក្នុងការពង្រឹង និង ពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ។ ជាក់ស្តែង នៅក្នុងឆ្នាំ ២០០៦ កន្លងទៅនេះ ប្រព័ន្ធធនាគារបានចូលរួមចំណែកចំនួន ៥០០ លានដុល្លារ ដើម្បីធ្វើហិរញ្ញប្បទានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ នេះ គឺជាលើកទីមួយហើយ ដែលប្រព័ន្ធធនាគារចូលរួមចំណែកជាហិរញ្ញប្បទានក្នុងទំហំប្រហាក់ប្រហែលនឹងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍក្រៅប្រទេសរបស់កម្ពុជា ។

27. សមិទ្ធផលល្អប្រសើរទាំងអស់នេះ បានផ្តល់នូវការលើកទឹកចិត្តយ៉ាងខ្លាំង ឱ្យរាជរដ្ឋាភិបាលបន្តជំរុញអនុវត្តនូវ «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥**» ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ កាលពីថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៧ កន្លងទៅនេះ ឱ្យបានជោគជ័យតាមការរំពឹងទុក ។ នៅក្នុងវិស័យនេះ អាទិភាពបន្តនៅក្នុងរយៈពេលមធ្យម នឹងត្រូវបានផ្តោតជាសំខាន់ទៅលើការពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារ ការពង្រីកវិសាលភាព និង ការកែលំអសេវាមីក្រូហិរញ្ញវត្ថុសម្រាប់ប្រជាជនក្រីក្រ និង សេវាមីក្រូឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងការជំរុញអភិវឌ្ឍស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារផ្សេងៗ រួមមានវិស័យធានារ៉ាប់រង ទីផ្សារមូលធន និង វិស័យភតិសន្យា ជាដើម ។

28. ការអភិវឌ្ឍន៍វិស័យឯកជន គឺជាមុខសញ្ញាកំណែទម្រង់ដ៏សំខាន់មួយទៀត ដែលកំពុងតែឈានទៅមុខទន្ទឹមគ្នានឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។ ថ្វីត្បិតតែយើងត្រូវខិតខំពុះពារជំនះឧបស័គ្គតូចធំច្រើនយ៉ាងណាក៏ដោយ ក៏ជារួម រាជរដ្ឋាភិបាលអាចសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយចំនួនធំដែរ នៅក្នុងកំណែទម្រង់អភិវឌ្ឍន៍វិស័យឯកជននេះ ពិសេសគឺនៅក្នុងការកែលំអយន្តការស្ថាប័ន និង ក្របខ័ណ្ឌគតិយុត្តិ និង និយ័តកម្ម ។ រាជរដ្ឋាភិបាលបានរៀបចំពង្រឹងឡើងវិញនូវយន្តការបញ្ជរតែមួយខាងផ្នែកវិនិយោគ និង សម្រេចបានជោគជ័យគួរជាទីមោទនៈជាច្រើន នៅក្នុងការងារសម្រួលពាណិជ្ជកម្ម និង វិនិយោគ រួមមាន ការកាត់បន្ថយពេលវេលាក្នុងការសុំអនុញ្ញាតវិនិយោគ ការកំណត់តម្លៃសេវាកម្មសាធារណៈឱ្យបានច្បាស់លាស់ ការកាត់បន្ថយតម្រូវការខាងផ្នែកវិញ្ញាបនប័ត្រផលិតកម្ម និង ការចុះត្រួតពិនិត្យធ្វើអធិការកិច្ចនានា ការកាត់បន្ថយតម្រូវការក្នុងការសុំអាជ្ញាប័ណ្ណផ្សេងៗ ការបំព្រួញបែបបទអន្តរស្ថាប័នក្នុងការត្រួតពិនិត្យទំនិញ ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហានិភ័យ និង ស្វ័យប្រវត្តិកម្មការងារគយ ការកាត់បន្ថយចំណាយក្រៅផ្លូវការក្នុងការរត់ការបំពេញបែបបទរដ្ឋបាល និង ការដាក់ចេញនូវបទដ្ឋានគតិយុត្តិ និង យន្តការស្ថាប័ន សម្រាប់អភិវឌ្ឍ និង គ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស ។ល។

29. នៅក្នុងរយៈពេលមធ្យមខាងមុខ ជាមួយនឹងភាពចាំបាច់ក្នុងការបន្តពង្រឹងសមិទ្ធផលដែលសម្រេចបានដូចខ្ញុំបានគូសរំលេចពីខាងលើ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់ពិសេសបន្ថែមទៀត ទៅលើការជំរុញអនុវត្តឱ្យបានរលូន នូវកម្មវិធីស្វ័យប្រវត្តិកម្មការងារគយ ដោយឈរលើមូលដ្ឋានកម្មវិធី «**អាស៊ីគូដា**» ការអនុវត្តឯកសាររដ្ឋបាលរួម ការបង្កើតបញ្ជរសេវាតែមួយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ការពង្រឹងតម្លាភាពនៃនីតិវិធីពាណិជ្ជកម្ម និង ការកែលំអរបបពន្ធដារ ឱ្យកាន់តែមានប្រសិទ្ធភាព និង តម្លាភាព ។

30. គ្មានការសង្ស័យទេថា នៅក្នុងបរិយាកាសនៃសុខសន្តិភាព និង ស្ថិរភាពដ៏ពេញលេញ និង គត់មត់ល្អប្រសើរ សមិទ្ធផលសំខាន់ៗ និង ភាពជឿនលឿនទាំងឡាយ នៅក្នុងវិស័យកំណែទម្រង់ទាំងប៉ុន្មានខាងលើនេះ បានចាក់ឫសយ៉ាងជ្រៅទៅក្នុងមូលដ្ឋាននៃសង្គម- សេដ្ឋកិច្ចកម្ពុជា និងបានធ្វើឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយជារួម ភាពក្រីក្ររបស់ប្រជាជនក៏ត្រូវបានកាត់បន្ថយជាបណ្តើរៗ ក្នុងល្បឿនដ៏គួរឱ្យកត់សម្គាល់ ។ ជាការពិត ទស្សនអនាគតប្រកបដោយក្តីសង្ឃឹមនៃការធ្វើអាជីវកម្មប្រេង- ឧស្ម័ន និង ធនធានរ៉ែដទៃទៀត បានបើកឱកាសសេដ្ឋកិច្ចថ្មី ដែលផ្តល់ក្តីសង្ឃឹមឱ្យកម្ពុជាអាចក្លាយទៅជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ថ្មីមួយទៀតនៅក្នុងតំបន់ ។ ប្រការទាំងអស់នេះ បង្ហាញអំពីឱកាសសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់

ប្រកបដោយចិរភាព នៅក្នុងរយៈពេលមធ្យម និង រយៈពេលវែង ព្រមទាំងនឹងជួយជំរុញឱ្យមានពិពិធកម្ម សេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រក្នុងល្បឿនកាន់តែឆាប់រហ័សជាងមុន ។

31. ពាក់ព័ន្ធនឹងលទ្ធភាពនៃការអាចទទួលបានចំណូលបន្ថែមពីអាជីវកម្មប្រេងនេះ កន្លងមក ខ្ញុំបានសង្កេតឃើញថា ដៃគូរបស់យើងហាក់ដូចជាមានការព្រួយបារម្ភជ្រុលបន្តិចអំពីការប្រើប្រាស់ចំណូលនេះ ថ្វីត្បិតប្រេង ឬ ឧស្ម័ននេះ វាកំពុងស្ថិតនៅក្រោមដីបាតសមុទ្រនៅឡើយ ហើយយើងមិនទាន់ទាំងដឹងថា ប្រេង ឬ ឧស្ម័ននេះ វាមានក្នុងបរិមាណប៉ុណ្ណានៅឡើយផង ដូចដែលខ្ញុំធ្លាប់រំលឹកជារឿយៗថា ***«ត្រីនៅក្នុងទឹក ដែលយើងមិនទាន់ ទាំងចាប់បានផង វាដូចជាមិនគួរទាន់ដល់ពេលចាត់ចែងថា ត្រីណាត្រូវអាំង ត្រីណាត្រូវស្ងោរនៅឡើយទេ»*** ។ ផ្ទុយទៅវិញ មានដៃគូរបស់យើងជាច្រើន និង មជ្ឈដ្ឋានខាងក្រៅផ្សេងទៀតមួយចំនួន បានសំដែងនូវការព្រួយ បារម្ភជាប់មិនដាច់ថា រាជរដ្ឋាភិបាលមិនបានត្រៀមខ្លួនល្អប្រសើរនៅឡើយទេ ដើម្បីចាត់ចែងប្រើប្រាស់ចំណូល នេះ ប្រកបដោយតម្លាភាព គណៈនេយ្យភាព និង ប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍន៍ប្រទេស ។ ការលើកឡើង ដដែលៗអំពីចំណុចនេះ នៅក្នុងពេលដែលចំណូលពីវិស័យប្រេងនេះ មិនទាន់មាននៅឡើយ និង ដោយមិន បានយកចិត្តទុកដាក់គិតគូរដល់ការខិតខំយ៉ាងប្តូរប្តេជ្ញរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញអនុវត្តកម្មវិធីកំណែ- ទម្រង់ដ៏មុតស្រួចទាំងឡាយក្នុងរយៈពេលកន្លងមក ដែលបានផ្តល់ជាលទ្ធផលដ៏ល្អប្រសើរ តាមរយៈការស្ទុះងើប ឡើងនៃសេដ្ឋកិច្ចជាតិ និង ការកាត់បន្ថយក្នុងល្បឿនគួរឱ្យកត់សម្គាល់នូវភាពក្រីក្ររបស់ប្រជាជន ក៏ដូចជា ដោយមិនបានកត់សម្គាល់ឃើញនូវការប្តេជ្ញាចិត្តជាសាធារណៈ និង ការអនុវត្តជាក់ស្តែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តជំរុញអនុវត្តកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយដាក់បញ្ចូលទៅក្នុងនេះផងដែរ នូវការគ្រប់គ្រងប្រកបដោយតម្លាភាព និង គណៈនេយ្យភាព នូវចំណូលដែលអាចទទួលបានពីវិស័យប្រេង និង ឧស្ម័ននេះ វាហាក់ដូចជាសរបញ្ជាក់ឱ្យឃើញអំពីការសង្ស័យឆាប់ពេកមួយចំនួនមកលើសុចរិតភាព និងសមត្ថភាព ក្នុងការគ្រប់គ្រង និង ដឹកនាំប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជា ។

32. យ៉ាងណាក៏ដោយ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីធ្វើការគូសបញ្ជាក់ជាថ្មីម្តងទៀត ជូនដៃគូទាំងអស់ឱ្យបានជ្រាបថា រាជរដ្ឋាភិបាលមានឆន្ទៈយ៉ាងមោះមុតក្នុងការធានាថា បើសិនជាទទួលបានមកមែន ទោះបីតិចក្តី ច្រើនក្តី ចំណូលពីប្រេង និង ឧស្ម័ននេះ នឹងត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណៈនេយ្យភាព នៅក្នុងក្របខ័ណ្ឌនៃថវិកាជាតិតែមួយ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដែលកំពុងតែត្រូវបានបន្តកែលំអឱ្យមានសភាពប្រសើរឡើងជាលំដាប់ សមស្របតាមស្តង់ដារនៃការអនុវតល្អប្រសើរជាអន្តរជាតិ ដើម្បីបម្រើឱ្យគោលដៅ និង សំណូមពរនៃការអភិវឌ្ឍប្រទេស ដូចមានចែងនៅក្នុង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**» របស់យើង ។

33. បន្ថែមពីលើនេះ ខ្ញុំយល់ថា នាពេលបច្ចុប្បន្ននេះ កម្ពុជាប្រហែលជាមានសេចក្តីត្រូវការចាំបាច់ក្នុងចរចា និង រៀបចំឱ្យបាននូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយ ដែលធានាផ្តល់ប្រយោជន៍ច្រើនបំផុតពីអាជីវកម្មវិស័យប្រេង និង ឧស្ម័ន និង វិស័យធនធានរ៉ែដទៃទៀត ជូនដល់កម្ពុជា ច្រើនជាងសេចក្តីត្រូវការក្នុងការគិតគូរថា តើកម្ពុជាត្រូវចាយវាយចំណូលពីប្រេង និង ឧស្ម័ននេះយ៉ាងដូចម្តេច ក្នុងពេលដែលចំណូលនេះមិនទាន់មាននៅឡើយ ?

ដូច្នេះ នៅពេលនេះ រាជរដ្ឋាភិបាលចង់ឃើញដៃគូអភិវឌ្ឍដែលមានការពាក់ព័ន្ធទាំងអស់ ផ្តល់ការយកចិត្តទុកដាក់ជួយដល់កម្ពុជា លើចំណុចរកចំណូលពីវិស័យនេះឱ្យបានច្រើន និង មានប្រសិទ្ធភាពបំផុត ទន្ទឹមនឹងចាប់ផ្តើមការពិភាក្សាពិគ្រោះយោបល់ជាមួយគ្នា អំពីរបៀបគ្រប់គ្រង និង ចាត់ចែងចំណូលដែលអាចទទួលបានពីវិស័យនេះ នៅក្នុងពេលអនាគតនោះ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

34. យើងទាំងអស់គ្នាបានដឹងហើយថា មូលដ្ឋានដ៏តូចចង្អៀតនៃកំណើនសេដ្ឋកិច្ចកម្ពុជា ដែលប្រមូលផ្តុំជាសំខាន់តែនៅតាមវិស័យមួយចំនួននៅក្នុងសេដ្ឋកិច្ចនៃទីប្រជុំជនធំៗ ក្នុងរយៈពេលកន្លងទៅនេះ គឺជាមូល-ហេតុដ៏ចម្បងមួយដែលបង្កើត និង បង្កើនវិសមភាពរវាងទីក្រុង និង ជនបទ ។ សេដ្ឋកិច្ចដែលពឹងអាស្រ័យខ្លាំងពេកទៅលើឧស្សាហកម្មកាត់ដេរ និង វិស័យទេសចរណ៍ ដែលជាវិស័យមានការប្រកួតប្រជែងដ៏តឹងតែង និងជាវិស័យងាយទទួលរងគ្រោះដោយសារកត្តាអស្ថិរភាពមួយចំនួនផ្សេងទៀត ពិតជាមានហានិភ័យខ្ពស់ណាស់ ។ ប្រការនេះ អាចធ្វើឱ្យពលករកម្ពុជាងាយនឹងបាត់បង់ការងារ ដែលជាហេតុអាចបណ្តាលឱ្យកើតមានវិបត្តិសង្គមជាច្រើនទៀតផ្សារភ្ជាប់ជាមួយនេះ ។ ដោយសារហេតុនេះហើយទើប «**យុទ្ធសាស្ត្រចតុកោណ**» របស់យើង បានកំណត់យកការជំរុញលើកស្ទួយវិស័យកសិកម្ម និង សេដ្ឋកិច្ចជនបទ ដែលពាក់ព័ន្ធទៅនឹងការរស់នៅរបស់ប្រជាជនកម្ពុជារហូតដល់ទៅជាង ៨០% ថាជាអាទិភាពដ៏ខ្ពស់បំផុតមួយ ។

35. យើងដឹងយ៉ាងច្បាស់ហើយថា បញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធ និង ឧបសគ្គដែលវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទកំពុងជួបប្រទះ មានទំហំធំធេងណាស់ ក្នុងនោះមានរួមបញ្ចូលនូវភាពងាយរងគ្រោះដោយសារកត្តាអាកាសធាតុ កង្វះខាតបណ្តាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តដឹកជញ្ជូនដែលមានប្រសិទ្ធភាព និង មានថ្លៃថោក កង្វះខាតប្រព័ន្ធស្រោចស្រព និង ការផ្គត់ផ្គង់អគ្គិសនី ការប្រែប្រួលនៃថ្លៃ និង ស្ថានភាពទីផ្សារកសិផល បញ្ហានៅក្នុងការគ្រប់គ្រងដីធ្លី ក៏ដូចជាបញ្ហានៅក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម ការបំពាក់បច្ចេកទេស និង បច្ចេកវិទ្យាសម្រាប់ការបង្ករបង្កើនផល ការប្រមូលផល និង ការថែរក្សាភោគផល ព្រមទាំងលទ្ធភាពឈានចូលទីផ្សារ និងសមត្ថភាពផ្នែកផ្គត់ផ្គង់ និង ឥណទាន ។ល។ ខ្ញុំសូមអនុញ្ញាតគូសរំលេចអាទិភាពចម្បងៗមួយចំនួន នៅក្នុងចំណោមកត្តាសំខាន់ៗទាំងអស់នេះ ។

36. ជាបឋម យើងត្រូវទទួលស្គាល់ថា ទឹកមានសារៈសំខាន់ខ្លាំងបំផុតសម្រាប់អាយុជីវិតរបស់ប្រជាជន និងសម្រាប់សេដ្ឋកិច្ចជនបទ ។ ទោះបីយើងមានគ្រាប់ពូជល្អ ដីមានប្រសិទ្ធភាព ការគ្រប់គ្រងកសិកម្មល្អប្រសើរ គ្រឿងយន្តទំនើប និង ដីមានជីជាតិយ៉ាងក៏ដោយ ប្រសិនបើគ្មានការគ្រប់គ្រងទឹកបានល្អប្រសើរ និង ប្រកបដោយប្រសិទ្ធភាពនោះទេ កត្តាទាំងអស់នេះ មិនអាចជួយឱ្យសេដ្ឋកិច្ចជនបទរីកចម្រើនបានទេ ។ ផ្ទុយទៅវិញ ការគ្រប់-គ្រងទឹកបានល្អ និង មានប្រសិទ្ធភាព អាចកាត់បន្ថយហានិភ័យផលិតកម្មបានយ៉ាងច្រើន ដែលប្រការនេះអាចជួយលើកទឹកចិត្តកសិករកម្ពុជា ឱ្យខិតខំ និង ហ៊ានធ្វើការវិនិយោគកាន់តែច្រើនឡើងលើគ្រាប់ពូជ គ្រឿងយន្ត ជី និង បច្ចេកទេសគ្រប់គ្រង ដើម្បីបង្កើនផលិតភាពរបស់ខ្លួន ។ នៅក្នុងបរិការណ៍នេះ ការរៀបចំបាននូវយុទ្ធ-សាស្ត្រវិស័យកសិកម្ម និង ទឹក គឺជាជំហានទៅមុខមួយយ៉ាងសំខាន់ នៅក្នុងការខិតខំ ដើម្បីលើកស្ទួយសេដ្ឋកិច្ច

និង ជីវភាពជនបទ ។ ដូច្នេះ តទៅមុខទៀត ការជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រនេះ គឺជាអាទិភាពដ៏សំខាន់បំផុត ដែលរាជរដ្ឋាភិបាលសូមអំពាវនាវឱ្យដៃគូទាំងឡាយរបស់ខ្លួន ផ្តល់ការយកចិត្តទុកដាក់ខ្ពស់ និង ចូលរួមផ្តល់នូវការគាំទ្រដ៏ចាំបាច់ទាំងឡាយ ឱ្យបានទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព ។

37. ជាការពិត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានខិតខំបង្វែរធនធានដែលមានកម្រិតរបស់ខ្លួនយ៉ាងច្រើន ទៅធ្វើការវិនិយោគនៅក្នុងវិស័យធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែពិនិត្យឃើញអំពីតម្រូវការ និង សក្តានុពលយ៉ាងធំធេងថែមទៀតរបស់កម្ពុជានៅក្នុងការអភិវឌ្ឍវិស័យកសិកម្ម និង ធនធានទឹកនេះ រួមជាមួយនឹងសេចក្តីត្រូវការដ៏ច្រើនលើសលុបថែមទៀតនៅក្នុងការកែលំអ និង អភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និង សង្គមដែលមានការពាក់ព័ន្ធ រួមមានបណ្តាញផ្លូវ-ស្ពាន បណ្តាញផ្គត់ផ្គង់អគ្គីសនី និង ទឹកស្អាតនៅតាមទីជនបទ សាលារៀន និង មន្ទីរសុខភាពសាធារណៈ ។ល។ ដូច្នេះ នៅក្នុងរយៈពេលមធ្យមខាងមុខ ការវិនិយោគកំហុគទៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធទាំងអស់នេះ នៅតែបន្តស្ថិតនៅជាអាទិភាពដ៏ចម្បងរបស់រាជរដ្ឋាភិបាល ហើយយើងខ្ញុំនឹងស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវិភាគទានដ៏សប្បុរសទាំងឡាយពីសំណាក់ដៃគូអភិវឌ្ឍន៍របស់យើង នៅក្នុងការខិតខំនេះ ។

38. រាជរដ្ឋាភិបាលមានការយល់ដឹងយ៉ាងច្បាស់ថា ធនធានធម្មជាតិ ជាពិសេសដី គឺជាមូលដ្ឋានដ៏សំខាន់បំផុតមួយ ដែលអាចយកមកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និង កាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតំបន់ជនបទ ។ លើមូលដ្ឋាននៃការគិតគូនេះ រាជរដ្ឋាភិបាលកំពុងតែដុតដៃដុតជើង ដើម្បីធ្វើការបំពេញបន្ថែមនូវក្របខ័ណ្ឌគតិយុត្តិ និង ពង្រឹងសមត្ថភាពស្ថាប័នរបស់ខ្លួន ក្នុងទិសដៅធានាឱ្យបាននូវប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិមួយ ដែលមានប្រសិទ្ធភាព និង តម្លាភាព ផ្អែកលើការចូលរួមពីសំណាក់គ្រប់តួអង្គដែលមានការពាក់ព័ន្ធ ហើយនិងធានាបាននូវការប្រើប្រាស់ប្រកបដោយចិរភាព ជាពិសេសសម្រាប់សហគមន៍នៅតាមមូលដ្ឋាន ។

39. នៅក្នុងការអនុវត្តច្បាប់ភូមិបាល និង គោលនយោបាយដីធ្លីរបស់ខ្លួន រាជរដ្ឋាភិបាលប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និង ដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និង ការដាក់ចេញវិធានការសមស្រប ដើម្បីទប់-ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់មិនធ្វើផលិតកម្ម ។ រាជរដ្ឋាភិបាលបាន និង កំពុងបន្តពិនិត្យឡើងវិញនូវដីទំនេររបស់រដ្ឋ ឬ ដីរដ្ឋដែលឯកជនកាន់កាប់ ដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្តិ និង នីតិវិធីដែលបានកំណត់កន្លងមក ដើម្បីប្រើប្រាស់ដីទាំងនោះឱ្យបានប្រកបដោយប្រសិទ្ធភាព ។

40. ជាការពិត រាជរដ្ឋាភិបាលក៏កំពុងតែមានកង្វល់យ៉ាងខ្លាំងដែរ ដោយពិនិត្យឃើញនូវរបាយការណ៍ថាហាក់ដូចជាមាននិន្នាការកើនឡើងនៃមជ្ឈការកម្មសិទ្ធិដីធ្លី និង ចំនួនប្រជាពលរដ្ឋដែលគ្មានដី ។ ដើម្បីដោះ-ស្រាយបញ្ហាដ៏ស្មុគ្រស្មាញនេះ រាជរដ្ឋាភិបាលនឹងបន្តខិតខំជំរុញការងារបែងចែក និង ផ្តល់កម្មសិទ្ធិដីធ្លីជូនដល់ប្រជាពលរដ្ឋ ពិសេសគឺប្រជាពលរដ្ឋក្រីក្រនៅតំបន់ឆ្ងាយៗដែលខ្វះដីពិតប្រាកដ ។ កន្លងមក នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីអភិវឌ្ឍន៍ខេត្ត-ក្រុង យើងបានធ្វើការកាត់យកដីរាប់សិបពាន់ហិកតា ពីតំបន់ព្រៃឈើរិចរិល ពីតំបន់ដី

ទំនេររបស់រដ្ឋ និង ពីផ្ទៃដីដែលឯកជនបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ យកមកធ្វើការបែងចែក និង ផ្តល់ជាកម្មសិទ្ធជូនដល់ប្រជាជនរាប់ពាន់គ្រួសារដែលគ្មានដីពិតប្រាកដ ដោយមានអមជាមួយនូវការវិនិយោគសាធារណៈនានា សំដៅធានាបង្កើតលក្ខខ័ណ្ឌនៃការរស់នៅសមរម្យ ជូនដល់ប្រជាជនដែលបានទទួលការតាំងទីលំនៅថ្មីនេះផងដែរ ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តគោលនយោបាយនេះ យ៉ាងសកម្មតទៅទៀត ដើម្បីដោះស្រាយបញ្ហាគ្មានដី ឬ ខ្វះខាតដី ជូនដល់បងប្អូនប្រជាជនដែលមានសេចក្តីត្រូវការពិតប្រាកដ ។ ខ្ញុំប្រើពាក្យ ***«ប្រជាជនដែលគ្មានដីពិតប្រាកដ»*** នេះច្រើនដង គឺក្នុងន័យចង់បញ្ជាក់ផងដែរ អំពីភាពចាំបាច់ក្នុងការខិតខំបញ្ចៀសឱ្យបាននូវបាតុភាពអវិជ្ជមាន ដែលកន្លងមកមានអ្នកនយោបាយខ្លះបានដើរធ្វើអាជីវកម្មបំផុសឱ្យប្រជាជនមួយចំនួនធ្វើការរំលោភចាប់យកដីរដ្ឋ ឬដីកម្មសិទ្ធិឯកជន ដោយខុសច្បាប់ តាមទិសស្លោក ***«ជោគជ័យ-បានដី, បរាជ័យ-បានលុយ»*** ។

41. បន្ថែមលើនេះទៀត យើងបាន និង កំពុងតែបន្តឹតបន្តឹងនូវការត្រួតពិនិត្យការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងទិសដៅធានាឱ្យបាននូវតម្លាភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងប្រភេទដីនេះ ស្របតាមគោលនយោបាយ និង លិខិតបទដ្ឋានជាធរមាន ។ ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចលុបកិច្ចសន្យា និងដកហូតយកមកវិញ នូវដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៥ ដែលមិនបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល និងតាមលិខិតបទដ្ឋានជាធរមាន ។

42. ជាការពិត ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** និង ឯកឧត្តមរដ្ឋមន្ត្រី **ចន្ទ សារុន** នឹងធ្វើការបំភ្លឺលម្អិតថែមទៀត ជូនដៃគូអភិវឌ្ឍន៍ទាំងអស់ជ្រាបអំពីគោលនយោបាយ និង ការអនុវត្តជាក់ស្តែងរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យកំណែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ និង ការគ្រប់គ្រងដីធ្លីនេះ ។ ក៏ប៉ុន្តែ ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនាពេលនេះ ខ្ញុំសូមធ្វើការណែនាំបន្ថែមជូនដល់ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរ សូមមេត្តារួមគ្នាពិនិត្យ ដោយសហការអាជ្ញាធរដែនដីដែលមានការពាក់ព័ន្ធ ដើម្បីដកយកផ្ទៃដីមួយចំនួនដែលមានលក្ខណៈសមស្រប ពីក្នុងផ្ទៃដីសម្បទានសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលទើបតែបានដកហូតយកពីក្រុមហ៊ុនទាំង ៥ នាពេលថ្មីៗកន្លងទៅនេះ យកមករៀបចំជាដីសម្បទានសង្គមកិច្ចសម្រាប់បែងចែកឱ្យបានឆាប់រហ័សជូនដល់ ***«ប្រជាពលរដ្ឋ ដែលគ្មានដីប្រើប្រាស់ពិតប្រាកដ»*** ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយណា ដែលមានការចាប់អារម្មណ៍ចង់ចូលរួមផ្តល់ការគាំទ្រចំពោះការអនុវត្តវិធានការនេះ ជាពិសេសធនាគារពិភពលោក ដែលបានធ្វើការសិក្សាលើការអនុវត្តគម្រោងនេះជាយូរមកហើយ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

43. រាជរដ្ឋាភិបាលវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់ដៃគូ ទៅលើការខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលគ្របដណ្តប់ទៅលើសូចនាករសង្គម- សេដ្ឋកិច្ចដ៏ទូលំទូលាយ ។ ចក្ខុវិស័យរយៈពេលវែងរបស់យើង គឺការកសាងសង្គមកម្ពុជាមួយដែលមានកោសិកាតភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងជ្រៅជ្រះ និង វប្បធម៌រឹងមាំ រួចផុតពីភាពក្រីក្រ និងភាពអវិជ្ជា ព្រមទាំងចាក

ផុតពីជម្ងឺដម្កាត់នានា ហើយអាចរួមរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនា និង គ្មានការរើសអើងគ្រប់ប្រភេទ ទាំងការរើសអើងខាងភេទ ជាតិសាសន៍ សាសនា និង ស្រទាប់វណ្ណៈក្នុងសង្គម ។

44. ដើម្បីគោលដៅនេះ យើងបានដាក់ចេញ និង អនុវត្តយ៉ាងម៉ត់ចត់នូវគោលនយោបាយសេដ្ឋកិច្ច- សង្គមជាកញ្ចប់មួយ សំដៅលើកស្ទួយស្ថានភាពនៃការរស់នៅជារួមរបស់ប្រជាជន រួមមាន ការធានាសន្តិសុខ និងសុវត្ថិ-ភាពក្នុងជីវភាពប្រចាំថ្ងៃ ការដោះស្រាយបញ្ហាវិសមភាពខាងផ្លូវភេទ និង ការអភិវឌ្ឍន៍សមត្ថភាព និង គុណភាពធនធានមនុស្ស តាមរយៈការកែលំអប្រព័ន្ធអប់រំ និង សិក្សាធិការ ក៏ដូចជាការកែលំអប្រព័ន្ធសេវាសុខភាពសា-ធារណៈ និង អនាម័យ ជាដើម ។ កន្លងមក រាជរដ្ឋាភិបាលបានប្រកៀកស្មាគ្នាយ៉ាងជិតស្និទជាមួយនឹងដៃគូដោយទាំងអស់គ្នា ពោលគឺ ទាំងរាជរដ្ឋាភិបាល ទាំងដៃគូ បានបង្ហូរនូវធនធានដ៏ច្រើនសន្ធឹកសន្ធាប់ទៅក្នុងវិស័យអភិវឌ្ឍន៍មនុស្សនេះ ។

45. ពិតណាស់ថា ជាលទ្ធផល យើងក៏សម្រេចបាននូវលទ្ធផលគួរជាទីកត់សម្គាល់ដ៏ច្រើនផងដែរ នៅតាមវិស័យសំខាន់នានា រួមមានដូចជា វិស័យអប់រំ សុខាភិបាល និង សុខភាពសាធារណៈ រាប់ទាំងការកាត់បន្ថយអត្រានៃឆ្លងជម្ងឺអេដស៍ផងដែរ ។ យ៉ាងណាក៏ដោយ យើងក៏ទទួលស្គាល់ផងដែរ នូវការខ្វះខាត និង បញ្ហាប្រឈមជាច្រើនទៀត ដែលយើងត្រូវពុះពារជំនះឱ្យខាងតែបាន ដើម្បីសម្រេចបានតាមចក្ខុវិស័យ និង គោលដៅដែលយើងបានដាក់ចេញមក ហើយទទួលយកទាំងអស់គ្នានេះ ។ ខ្ញុំរំពឹងថា អង្គប្រជុំរបស់យើងក្នុងរយៈពេលពីរថ្ងៃនេះនឹងផ្តល់ពេលវេលាសមរម្យសម្រាប់ការពិភាក្សាលើបណ្តាសមិទ្ធផល ក៏ដូចជាការខ្វះខាត និង បញ្ហាប្រឈមទាំងឡាយ ដែលយើងទាំងអស់គ្នាកំពុងតែជួបប្រទះនៅក្នុងវិស័យអភិវឌ្ឍន៍មនុស្សដ៏មានសារសំខាន់នេះ ។ សហការីរបស់ខ្ញុំនៅក្នុងរាជរដ្ឋាភិបាល ដែលជាអ្នកទទួលបន្ទុកផ្ទាល់លើកិច្ចការងារទាំងអស់នេះ នឹងធ្វើការពន្យល់បង្ហាញលម្អិត ជូនដល់ដៃគូទាំងអស់របស់យើង អំពីអ្វីដែលយើងទាំងអស់បានខិតខំរួមគ្នាសម្រេចបានមក អំពីអ្វីដែលជាយុទ្ធសាស្ត្រ និង ផែនការសម្រាប់ដោះស្រាយបញ្ហាដែលយើងកំពុងតែបន្តជួបប្រឈម និង អំពីសេចក្តីត្រូវការដ៏ចាំបាច់ទាំងឡាយ សម្រាប់ធានាជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រ និង ផែនការទាំងអស់នេះ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

46. ចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់នៅខែ ធ្នូ ឆ្នាំ ២០០៤ មក យើងសង្កេតឃើញមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅលើឆាកអន្តរជាតិ ពាក់ព័ន្ធនឹងការខិតខំដើម្បីដោះស្រាយបញ្ហាប្រសិទ្ធភាពនៃជំនួយ ។ ជាអន្តរជាតិ ស្តង់ដារថ្មីត្រូវបានបង្កើតឡើងសម្រាប់ទាំងអស់គ្នា ពោលគឺទាំងប្រទេសអភិវឌ្ឍន៍ និង ទាំងប្រទេសកំពុងអភិវឌ្ឍន៍ រួមមានសកម្មភាពដែលអាចត្រួតពិនិត្យបាន ហើយផ្តល់ផលក្នុងរយៈពេលវែង សំដៅកែទម្រង់វិធីផ្តល់ និង គ្រប់គ្រងជំនួយ ។

47. នៅផ្ទៃក្នុងប្រទេសវិញ រាជរដ្ឋាភិបាលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ហើយសម្រេចបាននូវវឌ្ឍនភាពជាច្រើនគួរឱ្យកត់សម្គាល់ ពិសេសគឺការពង្រឹងប្រសិទ្ធភាពការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ និង របស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ (GDCC) តាមរយៈការដាក់ចេញនូវ ***«ឯកសារណែនាំស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រុមការងារបច្ចេកទេស»*** ។ ជាក់- ស្តែង ការងារដ៏ចាំបាច់ទាំងឡាយដែលពាក់ព័ន្ធនឹងការត្រៀមរៀបចំ និង ប្រធានបទនានា

សម្រាប់ពិភាក្សាក្នុង វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកនេះ ព្រមទាំងស្ងួចនាករតាមដានរួមគ្នាទាំងឡាយ គឺសុទ្ធតែត្រូវ បានរៀបចំដោយរលូន តាមរយៈការប្រើប្រាស់យន្តការសម្របសម្រួលដែលត្រូវបានពង្រឹងបន្ថែមនេះ នៅក្នុង ស្មារតីនៃការទទួលស្គាល់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និង ដោយឈរលើមូលដ្ឋាននៃការពង្រឹងភាពជា ដៃគូពិតប្រាកដ និង គណនេយ្យភាពទ្វេទិសជាមួយដៃគូអភិវឌ្ឍន៍ ។

48. ខ្ញុំបានដឹងថា សម្រាប់ការប្រជុំរបស់វេទិកាយើងលើកនេះ គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) ដែលជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ (GDCC) និងជាលេខាធិការរបស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) បានរៀបចំនូវឯកសាររបាយការណ៍វិភាគលម្អិតមួយស្តីពី ***«ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ ២០០៧»*** ដែលបានគូសបញ្ជាក់យ៉ាងច្បាស់អំពីស្ថានភាពជាក់ស្តែង នៃការប្រើប្រាស់ និង ទទួលហិរញ្ញប្បទានសហប្រតិបត្តិការ បញ្ហាប្រឈមនានា និង អនុសាសន៍ដែលដៃគូទាំង សងខាងត្រូវយកចិត្តទុកដាក់បន្តអនុវត្ត ។ ខ្ញុំរំពឹងយ៉ាងមុតមាំថា របាយការណ៍នេះ នឹងទទួលបាននូវការយកចិត្ត ទុកដាក់ជាពិសេស ពីសំណាក់អង្គវេទិការបស់យើង តាមរយៈការពិភាក្សាស្វែងរកការឯកភាពគ្នាលើវិធានការ ជាក់ស្តែងនានា សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរបស់យើងឱ្យកាន់តែល្អប្រសើរឡើងថែម ទៀត ដោយឈរលើស្មារតីនៃភាពជាដៃគូដ៏ពិតប្រាកដ និង ការគោរពកាន់តែខ្លាំងឡើងនូវ ***«ភាពជាម្ចាស់»*** របស់កម្ពុជា ។

មុននឹងឈានទៅធ្វើការបូកសរុបបញ្ចប់សុន្ទរកថារបស់ខ្ញុំនេះ ខ្ញុំមានសំណើចុងក្រោយមួយទៀតដែលពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការប្រជុំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី ២ របស់យើង ។ ដូចអស់លោកអ្នកទាំងអស់គ្នាជ្រាបស្រាប់ នៅពាក់កណ្តាលឆ្នាំ ២០០៨ ខាងមុខនេះ នៅកម្ពុជានឹងមានការរៀបចំបោះឆ្នោតសកលសម្រាប់នីតិកាលថ្មីនៃរដ្ឋសភា ។ តាមបទពិសោធន៍កន្លងមក នៅក្នុងឆ្នាំដែលមានការបោះឆ្នោតសាកលបែបនេះ គឺយើងតែងឯកភាពគ្នារៀបចំការជួបប្រជុំរបស់យើងនៅចុងឆ្នាំ ដើម្បីទុកពេលគ្រប់គ្រាន់ឱ្យរដ្ឋាភិបាលថ្មីត្រៀមរៀបចំការងារ ។ ដូច្នេះ សម្រាប់ឆ្នាំ ២០០៨ ខាងមុខ យើងអាចពិនិត្យកំណត់យកពេលណាមួយសមស្រប ដែលមានរយៈពេលពីរថ្ងៃដដែល នៅក្នុងខែ ធ្នូ សម្រាប់ការប្រជុំនៃ «**វេទិកាកិច្ចសហប្រតិបត្តិការកម្ពុជា លើកទី ២**» ។ ចំពោះកាលបរិច្ឆេទពិតប្រាកដ ខ្ញុំយល់ថា យើងអាចនឹងពិគ្រោះឯកភាពគ្នាជាក់ស្តែង តាមរយៈយន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ។ ខ្ញុំរំពឹងលើការយោគយល់របស់អស់លោកអ្នកទាំងអស់គ្នា ចំពោះសំណើនេះ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

49. ខ្ញុំបានចំណាយពេលច្រើនគួរសម ដើម្បីលើកឡើងអំពីវិស័យសំខាន់ៗដែលមានការរីកចម្រើនកន្លងមក និង ផែនការសម្រាប់អនាគត ។ ពិតណាស់ថា ការបង្កើតយុទ្ធសាស្ត្រ និង គោលដៅនៅលើក្រដាស គឺជាជំហានដំបូងដ៏មានសារៈសំខាន់ ។ តែអ្វីដែលសំខាន់ជាងនេះ គឺការរៀបចំផែនការ និង ការអនុវត្តតាមរយៈសកម្មភាពជាក់ស្តែង ដើម្បីសម្រេចបានតាមយុទ្ធសាស្ត្រដែលបានកំណត់រួចហើយនេះ ។ ច្បាស់ណាស់ថា ការអនុវត្ត

ការងារជាក់ស្តែង គឺវាពិបាកខ្លាំងជាងការដែលគ្រាន់តែនិយាយ ។ យើងខ្ញុំខ្លួនឯងដឹងយ៉ាងច្បាស់ជាងអ្នកដទៃទៀតទាំងអស់ថា យើងនៅមានកំណាត់ផ្លូវដ៏វែងអន្លាយថែមទៀតដែលត្រូវធ្វើដំណើរទៅមុខ ។

50. កំណែទម្រង់មិនមែនគ្រាន់តែជាពាក្យនិយាយឱ្យរួចពីមាត់នោះឡើយ ។ ការអនុវត្តកំណែទម្រង់ មិនមែនតម្រូវឱ្យមានត្រឹមតែឆន្ទៈនយោបាយប៉ុណ្ណោះទេ ប៉ុន្តែ ក៏តម្រូវឱ្យមានធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុដ៏ច្រើនផងដែរ ។ បរិការណ៍វប្បធម៌ និង នយោបាយ ត្រូវតែបានយកមកគិតគូជាមួយគ្នា ។ ខ្ញុំទទួលស្គាល់នូវភាពមហិមានៃកិច្ចខិតខំប្រឹងប្រែង និង បញ្ហាប្រឈមមុខទាំងឡាយនៅចំពោះមុខយើង ។ ប្រការទាំងនេះ តម្រូវឱ្យតួអង្គពាក់ព័ន្ធទាំងឡាយចូលរួមទាំងអស់គ្នា គឺមិនមែនគ្រាន់តែសង្កេតការណ៍ និងទិតៀនប៉ុណ្ណោះទេ ។

51. រូបភាពរួមដែលខ្ញុំព្យាយាមបង្ហាញដល់អ្នកទាំងអស់គ្នាក្នុងថ្ងៃនេះ បានបង្ហាញពីចម្ងាយដែលកម្ពុជាបានធ្វើដំណើរជាង ១០ ឆ្នាំ ជាមួយនឹងការបង្កើនល្បឿនក្នុងរយៈពេលជិត ៤ ឆ្នាំចុងក្រោយ ដោយបានប្រែក្លាយប្រទេសមួយដែលដាច់ដោចដោយសារការបង្ហូរឈាម និងញាំញីដោយបញ្ហាក្រីក្រតោកយ៉ាក ឱ្យទៅជាប្រទេសដែលស្ថិតក្នុងជំហររឹងមាំលើផ្លូវនៃការរីកចម្រើន និង សម្រេចបានក្នុងការជាក់ស្តែង នូវសក្តានុពលពិតប្រាកដរបស់ខ្លួន ។ ក៏ប៉ុន្តែ គ្រប់ជំហានដែលយើងបានបោះទៅមុខ បានបង្ហាញនូវបញ្ហាប្រឈមថ្មីៗថែមទៀត ។ ទោះបីយ៉ាងនេះក៏ដោយ យើងបានសម្លឹងឃើញយ៉ាងច្បាស់នូវជើងមេឃនៃក្តីសង្ឃឹមរបស់យើង ហើយយើងនឹងប្រើគ្រប់វិធានការ ដើម្បីនាំកម្ពុជាទៅមុខឆ្ពោះទៅរកភាពកាន់តែប្រសើរឡើងសម្រាប់ប្រជាជនយើងខ្ញុំ ។

52. ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះការអត់ធ្មត់ និង យកចិត្តទុកដាក់របស់អស់លោកអ្នកទាំងអស់គ្នា ។ បំណងរបស់ខ្ញុំនៅពេលនេះ គឺធ្វើការធានាចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អំពីការ-ឯកភាព ការយោគយល់ និង ភាពហ្មឹងម៉ាត់នៃគោលបំណងរបស់យើង ក្នុងការអនុវត្តគោលនយោបាយ និងវិធានការចម្រើនជឿនលឿនទាំងឡាយ ដែលយើងបានដាក់ចេញមកដោយខ្លួនឯងផ្ទាល់ ។ ផ្លូវនៅខាងមុខមានសភាពកាន់តែច្បាស់ខ្លាំងឡើង ប៉ុន្តែ នៅតែវែងឆ្ងាយ និង លំបាកលំបិន ហើយសាមគ្គីភាពរបស់សហគមន៍អន្តរជាតិ ជាមួយសេចក្តីប្រាថ្នារបស់ប្រជាជនកម្ពុជា នៅតែបន្តមានតួនាទីស្លាប់រស់នៅលើមាគ៌ានេះ ។

53. ឯកឧត្តមទេសរដ្ឋមន្ត្រី ***គាត ឈន់*** ជាអ្នកដឹកនាំប្រកបដោយបទពិសោធន៍ និងពោរពេញដោយសមត្ថភាព នឹងតំណាងឱ្យរាជរដ្ឋាភិបាល ក្នុងការដឹកនាំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ១ នេះ ។ ដូចបានបញ្ជាក់ពីខាងលើ សហការីរបស់ខ្ញុំ នឹងនៅជាមួយអស់លោកអ្នក ហើយធ្វើការចែករំលែកជាមួយអស់លោកអ្នកទាំងអស់គ្នា នូវរាល់កម្មវិធី និងព័ត៌មានលម្អិតទាំងឡាយ ដែលទាក់ទិននឹងទិដ្ឋភាពនានាស្តីពីស្ថាន-ភាពសេដ្ឋកិច្ច- សង្គមកិច្ច និង សេចក្តីត្រូវការរបស់យើងខ្ញុំ ។

54. ខ្ញុំសូមជូនពរដល់អស់លោកអ្នកទាំងអស់គ្នា សូមប្រកបដោយសុខភាពល្អ និងជ័យជំនះក្នុងគ្រប់ភារកិច្ច និង សូមជូនពរឱ្យវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ១ នេះ ប្រព្រឹត្តិទៅបាន ប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ។

***ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់ !***